INSTITUT
DE CIVILISATION
INDIENNE
No Do 261

ព្រះរាជបណ្ណាល័យកម្ពុជា

# CAMPUCHÉA SAURIYA

# កម្ពុជសុរិយា

## សៀវភៅទស្សនាវដ្តីចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគំរប់បួន

ខ្សែ ១

កុង្សីយសេនាបតីបានអនុញ្ញាតហើយ.

PER
93

ក្រុងភ្នំពេញ
រោងពុម្ពអាល់ប៊ែរពរតៃ
គ្រិ. ឆ្នាំ ១៩៣១
ព. ស. ២៤៧៣

ÉCOLE FRANÇAISE
BIBLIOTHÈQUE
D'EXTRÊME ORIENT

អ្នកទទួលខុសត្រូវ : ជុំ-មៅ

# បញ្ជីរឿង

ទំព័រ


១ មិលិន្ទបញ្ហា ( តពីលេខ ១២ ឆ្នាំ ទី ៣ ) ព្រះឧត្តមមុនី អ៊ុម-ស៊ូរ
អាចារ្យនៅព្រះរាជបណ្ណាល័យកម្ពុជាប្រែពីបាឡី . . . . . . . . . . ៣

២ ប្រស្នាឩមិសត្វក្អែកនឹងដង្កូវ ព្រះញាណបវរវិជ្ជា អែម ចាងហ្វាងសាលាបាឡី
ជាន់ខ្ពស់ ប្រែពីបាឡីគម្ពីរបញ្ញាសជាតក ខ្សែ ១៨ . . . . . . . . . ១៧

៣ លោកធម៌ ៨ ប្រការ ព្រះសាសនសោភ័ណ ជួន-ណាត ចាងហ្វាងរង
សាលាបាឡីជាន់ខ្ពស់ ប្រែពីបាឡីហើយចងជាពាក្យកាព្យ. . . . . . ៣១

៤ រឿងសត្វខ្លា ដកយកពីរឿងព្រេងខ្មែរក្នុងសៀវភៅលោក អេម៉ូនិញេ . . . ៣៩

# TABLE DES MATIÈRES

Pages

1° Les questions de Milinda (suite du N° 12 de la 3e année) traduit du pàli en cambodgien par le Vénérable Préas Uttama Munî Oum-Sou, Achar à la Bibliothèque Royale ........................ 3

2° Dialogues entre le corbeau et la chenille, morceau choisi tiré de Paññâsajâtaka, fasc. XV et traduit du Pàli en cambodgien par le Vénérable Préas Nhéan Bavarvichéa Em, Directeur de l'Ecole Supérieure de Pàli ........ 17

3° Les huit Lokadharma, traduit du pàli et mis en vers par le Vénérable Préas Sàsanasobhana Chuon-Nath, Sous-Directeur de l'Ecole Supérieure de Pàli ........ 31

4° Contes cambodgiens recueillis par E. Aymonier, I — Histoire du Tigre ........................ 39

# រឿងមិលិន្ទបញ្ហា

ព្រះឧត្តមមុនី អ៊ុម-ស៊ូរ អាចារ្យនៅព្រះរាជបណ្ណាល័យកម្ពុជា

## ប្រែពីបាឡីមកជាភាសាខ្មែរ

## (១៣)

### វិញ្ញាណលក្ខណបញ្ហា ៗ ទី ១២

ព្រះមហាក្សត្រស្ដេចទ្រង់សួរទៅព្រះនាគសេនថេរថា បពិត្រលោកម្ចាស់ដ៏ចំរើន វិញ្ញាណដែលនឹងកើតឡើងនោះមាន លក្ខណដូចម្ដេចជាទីសំគាល់លោកម្ចាស់ ។

ព្រះនាគសេនថេរ ថ្វាយព្រះពរថា បពិត្រមហារាជ វិញ្ញាណដែលនឹងកើតឡើងនោះ មានកិរិយាដឹងផ្សេង ៗ ជា លក្ខណជាទីសំគាល់ សូមទ្រង់ជ្រាប ។

ម. សូមលោកម្ចាស់ ឧបមាបន្តិចមកមើល ។

ន. បពិត្រមហារាជ សេចក្ដីនេះប្រៀបដូចជារាជបុរសជា អ្នករក្សានូវព្រះនគរ រាជបុរសនោះទៅអង្គុយឬឈរនៅត្រង់ទីប្រជុំ

ផ្លូវទាំង ៤ ទិស ក៏តែងបានឃើញនូវមនុស្សម្នាមហាជនទាំងពួងដែលដើរមកអំពីទិស ខាងកើត, ខាងលិច, ខាងជើង, ខាងត្បូង គ្រប់ទាំង ៤ ទិសមិនខាន យ៉ាងណាមិញ បពិត្រមហារាជ សេចក្ដីនេះប្រៀបដូចបុគ្គលដែលឃើញនូវរូបដោយចក្ខុវិញ្ញាណ ឮនូវសំឡេងដោយសោតវិញ្ញាណ ធុំនូវក្លិនដោយឃានវិញ្ញាណ ភ្លក់នូវរសដោយជិវ្ហាវិញ្ញាណ ពាល់នូវសម្ផស្សដោយកាយវិញ្ញាណ ដឹងនូវធម៌ដោយមនោវិញ្ញាណ យ៉ាងនេះឯង បពិត្រមហារាជ ឯវិញ្ញាណដែលមានលក្ខណដឹងផ្សេងៗនោះ ដូចសេចក្ដីដែលពណ៌នាមកនេះ សូមមហាបពិត្រជ្រាប ។

ម. បូលបិត្តស្ដាប់បានហើយ លោកម្ចាស់ ។

វិតក្កលក្ខណបញ្ហា ។ ទី ១៣

ព្រះមហាក្សត្រស្ដេចទ្រង់សួរទៅព្រះនាគសេនថេរ ក្នុងវិតក្កបញ្ហាតទៅថា បពិត្រព្រះថេរដ៏ចំរើន វិតក្កចេតសិកនោះវេលាដែលនឹងកើតឡើងនោះតើ មានលក្ខណដូចម្ដេច ។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រមហារាជ វិតក្ក-
ចេតសិកនោះ វេលាដែលនឹងកើតឡើងនោះ មានកិរិយាអែប
ជិតនូវអារម្មណ៍ ឬតនូវអារម្មណ៍ ជាលក្ខណសូមទ្រង់ជ្រាប ។

ម. សូមលោកម្ចាស់ប្រៀបឧបមាបន្តិចមកមើល ។

ន. បពិត្រមហារាជ សេចក្ដីនេះឧបមាដូចជាងឈើដែល
តឈើ ធម្មតាជាងឈើដែលនឹងផ្ចាប់ឈើតគ្នានោះ តែងធ្វើ
មុខដំណនោះឡើងតស្និទ្ធល្អយ៉ាងណាមិញ ឯវិតក្កចេតសិក
នោះ ក៏តែងនឹងតផ្ចាប់នូវអារម្មណ៍ យ៉ាងនេះឯងជាលក្ខណ
សូមមហាបពិត្រជ្រាប ។

ម. ប្ញលបិត្តស្តាប់បានហើយលោកម្ចាស់ ។

វិចារលក្ខណបញ្ហា ៗ ទី ១៤

ព្រះបាទមិលិន្ទ ស្ដេចទ្រង់សួរព្រះនាគសេនថេរ ក្នុង
វិចារលក្ខណបញ្ហាទី ១៤ នេះតទៅទៀតថា បពិត្រព្រះនាគ
សេនម្ចាស់ ចុះវិចារចេតសិកនោះ តើមានលក្ខណយ៉ាងណា
លោកម្ចាស់ ។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រសម្ដេចមហារាជ

ឯវិចារចេតសិកនេះ វេលាដែលនឹងកើតនោះ មានកិរិយាបះ-
ពោសអង្អែល ឬមានកិរិយាត្រាប់ទៅតាមវិតក្កចេតសិកជា
លក្ខណា សូមទ្រង់ជ្រាប ។

ម. សូមលោកម្ចាស់ប្រៀបឧបមាជាសេចក្ដីបន្តិចមកមើល

ន. បពិត្រមហារាជ សេចក្ដីនេះប្រៀបដូចផ្ទៃនៃរគាំង
ដែលបុគ្គលយកដៃគោះហើយលាន់ឮជាសំឡេងតទៅ ឯត្រង់
កន្លែងដែលគោះនោះ ប្រៀបដូចវិតក្កចេតសិក ត្រង់សំឡេង
ដែលលាន់ឮតទៅនោះ ប្រៀបដូចវិចារចេតសិក ៗ នេះតែង
ប្រព្រឹត្តទៅតាមវិតក្កចេតសិកជាធម្មតា ដូចជាសំឡេងដែល
តែងប្រព្រឹត្តទៅឬកើតឡើង អំពីកិរិយាគោះនោះឯង សូម
មហាបពិត្រជ្រាប ។

ម. ព្រះថេរម្ចាស់ឆ្លៀវឆ្លាសពេកណាស់ ពេះប្រៀបឧបមា
ជាការងាយនូវលាយគំនិតនឹងគិតតាមបាន ។

## ក្នុងវគ្គទី ៤ នេះមានប្រស្នា ១០ ប្រការ

មនសិការបញ្ហា ។ ទី ១

ព្រះបាទមិលិន្ទ្រាធិរាជបរមក្សត្រ ស្ដេចទ្រង់ប្រារព្ធសួរទៅ

ព្រះនាគសេនថេរ ក្នុងប្រស្នាទី១ ក្នុងវគ្គទី៤នេះថា បពិត្រព្រះថេរដ៏ចំរើន មនសិការចេតសិកវេលាដែលនឹងកើតឡើងនោះ តើមានបែបយ៉ាងដូចម្តេច សម្រាប់សំគាល់ជាលក្ខណលោកម្ចាស់ ។

ព្រះនាគសេនថេរ ថ្វាយព្រះពរថា បពិត្រមហារាជ ឯមនសិការចេតសិកវេលាដែលនឹងកើតឡើងនោះ តែងក្រសាវរកនូវអារម្មណ៍ ឬនឹករកនូវអារម្មណ៍ជាលក្ខណជាបែបយ៉ាងសូមមហារាជស្តេចជ្រាប ។

ម. លោកម្ចាស់ឆ្លាសមែន, ខ្ញុំចូលចិត្តហើយ ។

ឯកភាវគតបញ្ហា ៗ ទី ២

ព្រះមហាក្សត្រស្តេចទ្រង់បុច្ឆាចំពោះទៅព្រះនាគសេនថេរក្នុងប្រស្នាទី ២ តទៅទៀតថា បពិត្រព្រះនាគសេនដ៏ចំរើនក៏ធម៌ទាំងឡាយមានផស្សជាដើមនេះឈ្មោះថាសហជាតធម៌ គឺជាជាធម៌តែងកើតព្រមគ្នាមិនមុនមិនក្រោយ ចុះបំណែកលោកម្ចាស់នឹងអាចបែកនូវធម៌ទាំងឡាយ ដែលមានកិរិយាកើតក្នុងទីជាមួយគ្នានេះ បញ្ញត្តិឲ្យជាធម៌ផ្សេង ៗ គ្នាថា សភាវនេះជាផស្ស, ធម្មជាតិនេះជាវេទនា, ធម្មជាតិនេះជាសញ្ញា, ធម្ម-

BIBLIOTHÈQUE D'EXTRÊME ORIENT

ជាតិនេះជាចេតនា, ធម្មជាតិនេះជាវិញ្ញាណ, សភាវនេះវិតក្ក, សភាវនេះជាវិចារ ដូច្នេះទៅបានឬមិនបានទេលោកម្ចាស់ ។

ព្រះនាគសេនថេរ ថ្វាយព្រះពរថា បពិត្រសម្ដេចមហារាជ ឯសហជាតធម៌ទាំងឡាយនេះ អាត្មាភាពមិនអាចនឹងញែកបែកហើយធ្វើកុំណត់ឲ្យផ្សេង ៗ គ្នាថា សភាវនេះជាផស្ស, ធម្មជាតិនេះជាវេទនា, ធម្មជាតិនេះជាសញ្ញា, ធម្មជាតិនេះជាចេតនា, ធម្មជាតិនេះជាវិញ្ញាណ សភាវនេះជាវិតក្ក, សភាវនេះជាវិចារ ដូច្នេះនោះបានឡើយ ។

ម. ឧបមំ ករោហិ សូមលោកម្ចាស់ធ្វើនូវសេចក្ដីឧបមាបន្តិចមក នឹងស្ដាប់មើលលោកម្ចាស់ ។

ន. យថា មហារាជ បពិត្រសម្ដេចមហារាជសេចក្ដីនេះប្រៀបដូចអ្នកក្រួឬពួករំសេសរបស់មហាក្សត្រាធិរាជ ដែលជាអ្នកធ្វើនូវកិរិយាព្រះស្ងោយថ្វាយ កាលដែលនឹងស្លរឬញាំ, ធានោះគេតែងបង់នូវគ្រឿងផ្សេង ៗ ចូលគ្នា មានដាក់ទឹកដោះជូរ, អម្បិល, ខ្ញី, ជីរក៏ នឹងម្ទេសជាដើម ហើយនឹងវត្ថុដទៃ ៗ ដែលជារបស់វិសេសនោះទៅក្នុងឆ្នាំងសំឡរឬធានោះ លុះរួចស្រេចហើយទើបលើកចូលទៅថ្វាយព្រះមហាក្សត្រ ចំណែកមហា-

ក្សត្រសោត ស្តេចនឹងបង្គាប់ទៅពួកវិសេសនោះថា អ្នកទាំងឡាយចូរអ្នកនាំមកនូវរសនៃទឹកដោះជូរក្នុងទឹកសំឡរនោះមកឲ្យយើង ហើយនាំនូវរសនៃទឹកអម្បិល, នឹងរសនៃខ្ញី, នឹងរសនៃជីរក៍, នឹងរសនៃម្ទេស ដែលជារបសធ្លាញ់ៗ ដែលអ្នកទាំងឡាយបង់បុះហើយ ក្នុងឆ្នាំងសំឡរនោះមកឲ្យយើង បពិត្រមៈហារាជ បើមហាក្សត្រស្តេចបង្គាប់យ៉ាងហ្នឹងហើយ ពុះបំណែកខាងពួកវិសេសនឹងអាចចាត់បែងចែកនូវរសនៃវត្ថុទាំងឡាយដែលច្រឡូកច្រឡំគ្នាក្នុងឆ្នាំងសំឡរនោះ ហើយនឹងនាំយកនូវរសជូរ ឬរសប្រៃ, រសល្វីង, រសហិល, រសចត់នឹងរសផ្អែមជាដើម មកថ្វាយមហាក្សត្របានឬទេ មហាបពិត្រ ។

ម. នហិភន្តេ បពិត្រព្រះបេរដ៍បំរើន ពួកវិសេសទាំងនោះ មិនអាចនឹងញែកបែកនូវរសជូរនឹងរសប្រៃជាដើមដែលខ្លួនបង់បុះជាមួយគ្នាក្នុងទឹកសំឡរនឹងនាំយកមកថ្វាយមហាក្សត្រនោះបានឡើយ ។

ន. ឯវមេវខោមហារាជ បពិត្រសម្តេចមហារាជ ក៏ពួកអ្នកក្រ្ហ ឬពួកវិសេសដែលមិនអាចនឹងញែកបែកនូវរសនៃទឹកសំឡរដែលជ្រាបចេញពីវត្ថុទាំងឡាយមានអម្បិលនឹងអម្ពិលជា

ដើម ដែលខ្លួនបង់បុះក្នុងឆ្នាំងសំឡរនោះយ៉ាងណា, អាត្មាភាពនេះក៏មិនអាចនឹងញែកបែកនូវធម៌ទាំងឡាយមានផស្សជាដើមដែលកើតព្រមគ្នា ហើយធ្វើឲ្យផ្សេងគ្នាថា នេះផស្ស, នេះវេទនា, នេះសញ្ញា, នេះចេតនា, នេះវិញ្ញាណ, នេះវិតក្ក, នេះវិចារ នោះបានឡើយ យ៉ាងនោះឯងសូមថ្វាយព្រះពរ ។

លំដាប់ពីនោះទៅទើបព្រះថេរថ្វាយព្រះពរសួរទៀមហាក្សត្រថា បពិត្រព្រះរាជសម្ភារ បុះអម្បិលដែលគេត្រូវដឹងនោះតើត្រូវដឹងដោយចក្ខុឬអ្វីមហាបពិត្រ ។

ម. ករុណាលោកម្ចាស់ អម្បិលនោះគេត្រូវដឹងដោយចក្ខុយ៉ាងហ្នឹងហើយ ។

ន. សុដ្ឋុខោមហារាជ បពិត្រសម្តេចមហារាជ ព្រះរាជឱង្ការដែលទ្រង់ត្រាស់ថា កិច្ចដែលគេដឹងរសអម្បិលនោះ គឺដឹងដោយចក្ខុវិញ្ញាណ ព្រះតម្រាស់នេះ សូមទ្រង់ត្រាស់ឲ្យប្រាកដដោយល្អ កុំប្រែប្រួល ។

ម. កឹភន្តេ បពិត្រព្រះថេរដ៏ចំរើន បុះលោកម្ចាស់សំគាល់ថាគេដឹងដោយអ្វី ថាគេដឹងដោយជីវ្ហាឬអ្វី ។

ន. អាមមហារាជ បពិត្រមហារាជ អាត្មាភាពចូលចិត្ត

ថា គេដឹងនូវអម្បិលនោះ គឺដឹងដោយជីវ្ហាវិញ្ញាណជាប្រាកដ សូមមហាបពិត្រជ្រាប ។

ម. កឹបនភន្តេ បពិត្រព្រះនាគសេនថេរដ៏ចំរើន ចុះលោកម្ចាស់សំគាល់ថា បុគ្គលដែលដឹងនូវអម្បិលទាំងអស់នោះ គឺដឹងដោយជីវ្ហាឬអ្វី ។

ន. អាមមហារាជ បពិត្រមហារាជ អាត្មាភាពសំគាល់ថាបុគ្គលដែលដឹងនូវអម្បិលទាំងអស់នោះគឺដឹងដោយជីវ្ហា តែអញ្ជាំងប៉ុណ្ណោះសូមទ្រង់ជ្រាប ។

ម. បើលោកម្ចាស់ថា គេដឹងដោយជីវ្ហា ចុះប្រសិនបើគេយករទេះទៅផ្ទុកអម្បិលពេញក្នុងរទេះហើយ គេដឹកនាំមកកាន់ទីចំពោះមុខ បើត្រូវការចង់ដឹងនូវអម្បិលនោះ តើយើងត្រូវធ្វើដូចម្តេច គឺគ្រាន់តែមើលដោយភ្នែកទៅដឹង ឬៗ ចាំយកជីវ្ហាទៅលិតភ្លក់មើល ទើបដឹងលោកម្ចាស់ ។ ម្យ៉ាងទៀតអម្បិលក្នុងរទេះដែលគេតែងនាំមកដោយគោមានកំឡាំង ចុះបំណែកជីវ្ហានឹងអាចនាំមកនូវអម្បិលទាំងរទេះបានឬពុំបានទេលោកម្ចាស់ ។

ន. បពិត្រមហារាជ ឯជីវ្ហានេះមិនអាចដឹកនាំមកនូវអម្បិលទាំងរទេះនោះបានឡើយ ព្រោះអម្បិលនោះធ្ងន់ហួសកំឡាំងនៃ

អណ្ណាត សេចក្ដីនេះដូចគ្នានឹងសហជាតធម៌ទាំងឡាយ មានផស្សជាដើម ដែលជាធម៌តែងកើតឡើងព្រមគ្នា ឬតែងកើតក្នុងទីជាមួយគ្នា តែងមានអារម្មណ៍ផ្សេង ៗ គ្នា ដែលអាត្មាភាពបានថ្វាយព្រះពរហើយថា បញ្ញាអាត្មាភាពមិនអាចនឹងញែកបែកនូវធម៌ទាំងនោះឲ្យផ្លែកគ្នាបានទេ ម្យ៉ាងទៀត អាត្មាភាពសូមថ្វាយព្រះពរសួរមហាបពិត្រវិញថា បុះអម្បិលទាំងរទេះនោះ បុគ្គលនឹងអាចថ្លឹងដោយជញ្ជីង បានឬពុំបានទេ មហាបពិត្រ ។

ម. អម្បិលក្នុងរទេះនោះ បុគ្គលនឹងអាចថ្លឹងដោយជញ្ជីងបាន លោកម្ចាស់ ។

ន. បុះមហារាជស្ដេចជ្រាបថា ប្រាកដជាថ្លឹងដោយជញ្ជីងបានយ៉ាងហ្នឹងឬអ្វី ។

ម. បុះលោកម្ចាស់យល់ដូចម្ដេច ថាមិនអាចថ្លឹងបានឬអ្វី

ន. ថ្វាយព្រះពរ អាត្មាភាពថាមិនអាចនឹងថ្លឹងដោយជញ្ជីងបាន ព្រោះអម្បិលទាំងរទេះនោះមានភារធ្ងន់ដោយច្រើន

ឯការដែលនឹងថ្លឹងនូវរបស់ទាំងពួងនោះ គួរដល់កំឡាំងជញ្ជីង ទើបនឹងថ្លឹងបាន បើវត្ថុនោះធ្ងន់ពេកហួសកំឡាំង ក៏មិនអាចនឹងថ្លឹងបានឡើយ មិនមែនជាកិច្ចការត្រូវប្រែកបទេ ប្រៀបដូចជាដីភ្លូដែលមិនអាចនឹងដឹកតាមកនូវអម្បិលទាំងរទេះនោះឯង សេចក្ដីនេះគួរនាយ៉ាងណាមិញ ឋាព្រះរាជឱង្ការដែលត្រាស់ឲ្យអាត្មាភាពញែកបែកនូវសភាវធាតុធម៌ទាំងឡាយមានផស្សជាដើម ដែលជាធម៌តែងកើតឡើងព្រមគ្នានោះឲ្យផ្សេងចេញពីគ្នា ឬផ្ដែកចេញពីគ្នានោះពុំបានទេ ដូចគ្នានឹងអម្បិលដែលបុគ្គលផ្ទុកបុះក្នុងរទេះ ហើយឲ្យអណ្ដាតទៅដឹកតាមកទាំងរទេះពុំបាននោះ សូមថ្វាយព្រះពរ ។

ម. កល្ហោសិ ព្រះថេរនេះ លោកឆ្លាសពេកណាស់បេះដោះសារគួរឲ្យចូលចិត្តបាន ។

បញ្ហាយគនកម្មទិព្វគ្គបញ្ហា ។ ទី ៣

ព្រះមហាក្សត្រស្ដេចទ្រង់បុច្ឆាចំពោះទៅព្រះនាគសេនថេរ ក្នុងប្រស្នាទី ៣ ក្នុងវគ្គទី ៤ នេះថា បពិត្រព្រះថេរដ៏ចំរើន ខ្ញុំមាន

សេចក្ដីសង្ស័យត្រង់អាយតនទាំង ៥ ប្រការ គឺកន្លែងដែលជាទីកើតនៃវិញ្ញាណទាំង៥នោះ អាយតនទាំង៥ប្រការនេះ វេលាដែលនឹងកើតឡើងនោះជានឹងកើតឡើងដោយកម្មផ្សេង ៗ គ្នា ឬៗនឹងកើតឡើងដោយកម្មតែម្យ៉ាងជាមួយគ្នាទេ លោកម្ចាស់។

ព្រះនាគសេនថេរ ថ្វាយព្រះពរទៅវិញថា បពិត្រសម្ដេចមហារាជ ឯអាយតនទាំង ៥ ប្រការនឹងបានកើតដោយកម្មផ្សេង ៗ គ្នាក៏ទេ គឺកើតឡើងដោយកម្មតែម្យ៉ាងជាមួយគ្នា សូមទ្រង់ជ្រាប ។

ម. ឧបមំករោហិ សូមលោកម្ចាស់ឧបមាបដិបមក់នឹងស្ដាប់មើល ។

ន. ឯកស្មិំខេត្តេ បពិត្រព្រះរាជសម្ភារ សេចក្ដីនេះប្រៀបដូចពូជស្រូវទាំង ៥ យ៉ាងដែលបុគ្គលព្រោះព្រោះបណ្ដុះទៅក្នុងស្រែតែ ១ ហើយពូជទាំងនោះក៏ដុះដាលឡើងអំពីស្រែជាមួយគ្នា វេលាដល់បេញជាផ្លែ ក៏ផ្លែផ្សេង ៗ ពីគ្នា សេចក្ដីនេះគួរនាយ៉ាងណាមិញ បពិត្រមហារាជ ថាគួរនាដូច អាយ-

តនទាំងឡាយ ៥ ប្រការ ក៏អោយតនទាំង ៥ នេះនឹងបានកើត ដោយកម្មផ្សេង ៗ គ្នានោះក៏ទេ គឺកើតដោយកម្មតែម្យ៉ាង ជាមួយគ្នាដូចពូជស្រូវទាំង៥ដែលកើតក្នុងស្រែតែ ១ នោះឯង សូមទ្រង់ជ្រាប ។

ម. ខ្ញុំបួលចិត្តស្តាប់បានហើយលោកម្ចាស់ អស់សង្ស័យក្នុងចិត្តហើយ ។

( មានតទៅទៀត )

# ប្រស្នាធម៌

ព្រះញាណបវរវិជ្ជា អែម ចាងហ្វាងសាលាបាលីជាន់ខ្ពស់នៅក្រុងភ្នំពេញ

រៀបរៀង

— ១ —

## ប្រស្នាសត្វក្អែកនិងជង្ហុវ

### នមស្សការ

នមត្ថុរតនត្តយស្ស តស្សានុភាវេន សព្វសោត្ថី ភវន្តុ មេ ។

(ប្រែ) កិរិយានមស្ការនៃខ្ញុំព្រះករុណាចូរមានដល់ប្រជុំបីនៃរតនគឺ ព្រះពុទ្ធរតន, ព្រះធម្មរតន, ព្រះសំឃរតន, ដោយសេចក្ដីគោរព, សូមសេចក្ដីសួស្ដីទាំងពួង កើតមានដល់ខ្ញុំព្រះករុណា ដោយអានុភាពនៃព្រះរតនត្រៃនោះ ។

ខ្ញុំព្រះករុណាអាត្មាភាព សូមជ្រើសរើសដកស្រង់យកសេចក្ដីធម៌និងប្រស្នាធម៌ ដែលមានក្នុងគម្ពីរព្រះសូត្រផ្សេងៗ ជាភាសាបាឡីសុទ្ធ ដែលជាគ្រឿងប្រដាប់ញ៉ាំងសេចក្ដីឆ្លាសវៀង

BIBLIOTHÈQUE D'EXTRÊME ORIENT

វៃឲ្យកើតឡើងដល់អ្នកសិក្សា ប្រែបំប្រួញសេចក្ដីឲ្យខ្លីចុះមកជាភាសាខ្មែរ រៀបរៀងជាសេចក្ដីយ៉ាងសង្ខេប ល្មមនឹងសិក្សាបានដោយងាយ ដើម្បីជាប្រយោជន៍ដល់ពុទ្ធសាសនិកជនដែលជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា ដូចមានរបៀបរឿងខាងក្រោយនេះសព្វគ្រប់ស្រាប់ ។

១ – សំដែងអំពីបណ្ហារិសង្គនានៃសត្វក្អែកនឹងសត្វដង្កូវមានក្នុងគម្ពីរ បញ្ញាសជាតកខ្សែ ១៥ អធិប្បាយថា៖

កាលសម្ដេចព្រះសមណគោត្រជិនស្រី ព្រះអង្គគង់នៅក្នុងវិហារព្រះជេតពន៍សុគន្ធកុដី ទៀបក្រុងសាវត្ថី សម័យនោះមានសត្វក្អែកមួយ ហើរត្រេចទៅកាន់បទេសហិមពាន្ត បានដល់ទីលំនៅនៃសត្វដង្កូវធំ ១ ឃើញនូវសត្វដង្កូវនោះហើយគិតថា៖

" ឱហ្ន៎ បំណាំអញបានហើយតើ " ហើយហើរចុះទៅកាន់ទីជិតនៃសត្វដង្កូវធំនោះ ពោលទៅនឹងសត្វដង្កូវថា៖

" ភោមហាកិមិន ម្នាលសត្វដង្កូវធំ អញនឹងស៊ីអ្នកឥឡូវនេះ "

– ឯសត្វដង្កូវធំបានឮហើយ ក្រឡេកមើលទៅសត្វក្អែកនោះ ហើយបែត្រឡប់ពោលតបទៅនឹងសត្វក្អែកនោះវិញថា៖

"ហាវ កាក នែវើយសត្វក្អែកបង្រៃ ឯងចេះដឹងអ្វីដែរ បាន ជាឯងគិតស៊ីអញជាចំណីឯង"

សត្វក្អែកស្តាប់ហើយពោលតបវិញថា: "មហាកិមិន ម្នាលសត្វដង្កូវធំ ចុះឯងចេះដឹងអ្វីខ្លះ"

សត្វដង្កូវធំឮហើយពោលថា "នែសត្វក្អែកបង្រៃ អ្នក មិនដឹងទេឬ អញនេះចេះដឹងច្រើនណាស់"

សត្វក្អែកស្តាប់ហើយពោលថា: "វើយសត្វដង្កូវ បើឯង ចេះដឹងច្រើន ឯងពោលបំណោះឯងមកមើល ឃុំណោះឯងអ្វីខ្លះ"

សត្វដង្កូវឆ្លើយថា: "អញចេះបញ្ហា ៤ បំពូក អញ នឹងសួរបញ្ហា ៤ បំពូកនឹងអ្នកឯង"

សត្វក្អែកឆ្លើយថា "បើឯងចេះ ឯងសួរអញមកចុះអញ នឹងឆ្លើយ"

សត្វដង្កូវពោលថា: "ម្នាលសត្វក្អែក បើឯងចេះឆ្លើយ តបបញ្ហាអញរួច ហើយឯងស៊ីអញទើបប្រពៃ បើឯងមិនចេះ ទេហើយស៊ីអញជាចំណី ក្បាលឯងនឹងបែកជាប្រាំពីរភាគ"

សត្វក្អែកពោលថា "ម្នាលសត្វដង្កូវធំដ៏ចំរើន អ្នកឯង ចូរសួរបញ្ហានោះមកចុះ អញនឹងឆ្លើយតបអ្នកឥឡូវនេះ"

សត្វដង្កូវពោលថា : "ម្នាលសត្វក្អែកដ៏ចំរើន បញ្ហា ១ ថាធំហើយក្រៃលែងជាងធំ គឺអ្វី"

សត្វក្អែកឆ្លើយដោះបញ្ហាថា : "ទេវតាជាបុគ្គលធំដោយវិសេសជាងបុគ្គលដទៃ"

ឯសត្វដង្កូវធំស្ដាប់ហើយពោលថា: "ម្នាលសត្វក្អែកអ្នកឯងមិនបេះមិនដឹងអ្វីឡើយ ឆ្លើយមកពុំត្រូវទេ អញនឹងសួរបញ្ហា ១ តទៅទៀត ថារហាស់ហើយរហាស់ក្រៃលែងគឺអ្វី"

សត្វក្អែកឆ្លើយថា: "សត្វសេះអស្សតរ ជាសត្វរហាស់ក្រៃលែងរហាស់"

ឯសត្វដង្កូវធំស្ដាប់ហើយពោលថា "អ្នកឯងមិនបេះមិនដឹងអ្វីឡើយ ឆ្លើយមកពុំត្រូវទេ អញនឹងសួរបញ្ហា ១ ទៀតថា: ធម្មជាតិឆាប់ហើយមុតក្រៃលែងគឺអ្វី"

ឯសត្វក្អែកព្យាករណ៍ឆ្លើយថា : "កូនសរទាំងឡាយជាធម្មជាតមុតក្រៃលែងមុត"

ឯសត្វដង្កូវធំស្ដាប់ហើយពោលថា : "អ្នកឯងមិនបេះមិនដឹងអ្វីឡើយ ឆ្លើយមកពុំត្រូវទេ អញនឹងសួរបញ្ហា ១ ទៀតថា: ខ្លាំងហើយខ្លាំងក្រៃលែងគឺអ្វី"

ឯសត្វក្អែកព្យាករណ៍ឆ្លើយថា: "ព្រះនារាយណ៍ជាបុគ្គលខ្លាំងក្រៃលែងខ្លាំង"

ឯសត្វដង្កូវធំស្ដាប់ហើយពោលថា: "ម្នាលសត្វក្អែកកំណាចចង្រៃ អ្នកឯងគ្មានចេះដឹងអ្វីសោះឡើយ បណ្ដាបញ្ហាទាំង ៤ បំពួកនេះ សូម្បីតែបញ្ហា ១ ក៏អ្នកឯងគ្មានដឹងសោះ អ្នកឯងនឹងស៊ីអញដូចម្ដេចបាន តែអ្នកឯងស៊ីអញហើយក្បាលអ្នកឯងនឹងបែកជា ៧ ភាគ បុគ្គលណាមួយឈ្មោះថាអាចនឹងដោះប្រស្នានេះ ក្នុងលោកនេះពុំមានទេ វៀរលែងតែព្រះតថាគតចេញ ម្នាលសត្វក្អែកកំណាចចង្រៃ បើអ្នកឯងចង់ស៊ីអញមានតែអ្នកឯងនាំអញទៅកាន់សំណាក់ព្រះដ៏មានព្រះភាគ ទើបព្រះសាស្ដាព្រះអង្គនឹងសំដែងដោះស្រាយបញ្ហានេះឲ្យជាក់ច្បាស់បាន បើពាក្យអ្នកឯងសមគួរមែន ទើបអ្នកឯងនឹងស៊ីអញជាបំណាំបាន ។

រីឯសត្វក្អែកបានពោលទៅនឹងដង្កូវធំថា ."ភោ កិមិន ម្នាលដង្កូវធំដ៏ចំរើន ចំណែកខាងអញនឹងទៅកាន់សម្នាក់ព្រះដ៏មានព្រះភាគដោយឆាប់រហាស់បាន ចំណែកខាងអ្នកវារតែនឹងដើរ ៗ អាចទៅដូចម្ដេចបាន" ។

ឯសត្វជង្ហូវនោះពោលទៅនឹងសត្វក្អែកវិញថាៈ "ម្នាលសត្វក្អែក អ្នកឯងត្រូវស្វែងរកវល្លិបានហើយត្រូវយកមកបង់អញពាក់កណ្ដាលខ្លួន ហើយអ្នកឯងត្រូវពាំចុងវល្លិម្ខាង ហើរទៅតាមអាកាសហើយអញបុះក្នុងសម្នាក់ព្រះដ៏មានព្រះភាគ" ។

ឯសត្វក្អែកក៏បានធ្វើតាមបង្គាប់សត្វជង្ហូវ ហើយហើរនាំទៅកាន់សម្នាក់ព្រះដ៏មានព្រះភាគ ។

សម័យនោះសម្ដេចព្រះភគវន្តមុនីសម្ពុទ្ធម្ចាស់ ព្រះអង្គទ្រង់រមិលមើលនូវសត្វលោក បានជ្រាបច្បាស់នូវសត្វទាំង ២ នោះហើយញញឹមបំពោះទៅនឹងព្រះថេរឈ្មោះអានន្ទ ។

ឯព្រះថេរឈ្មោះអានន្ទ បានឃើញព្រះអង្គទ្រង់ញញឹមនោះហើយ ក៏សួរថា "បពិត្រព្រះអង្គដ៏ចំរើន មានហេតុអ្វីមានបច្ច័យអ្វី បានជាព្រះអង្គទ្រង់ញញឹម"

ឯសម្ដេចព្រះធម្មិស្សរញាណសម្ពុទ្ធ ព្រះអង្គមានពុទ្ធដីកាថាៈ "ម្នាលភិក្ខុឈ្មោះអានន្ទ សេចក្ដីអស្ចារ្យ ១ នឹងកើតមានប្រាកដ ចូរអ្នករង់ចាំបន្តិចសិនចុះគង់នឹងឃើញពិត ។

គ្រានោះសត្វក្អែក នាំសត្វជង្ហូវទៅដល់ព្រះវិហារជេតពនហើយដាក់សត្វជង្ហូវនោះចុះដល់ដី ស្រាយបំណងដែលខ្លួន

បងដង្ហូវរូបហើយចូលទៅកាន់សំណាក់ព្រះបរមសាស្តា ហើយក៏ឈរនៅ ។

រីសត្វដង្កូវបានលាតសណ្ឋានខ្លួនត្រង់ ហើយវារទៅតិច ៗ បានដល់សម្នាក់ព្រះដ៏មានព្រះភាគ ហើយពោលជាបទព្រះគាថាថា: "ភន្តេបិភគវាសេដ្ឋ សព្វលោកហិតាករ សព្វកាលទយាតិណ្ណ សព្វសោត្ថីភវន្តុមេ ( ប្រែថា:) ខ្ញុំសូមសរសើរ បពិត្រព្រះដ៏មានព្រះភាគដ៏ចំរើន ព្រះអង្គប្រសើរដោយវិសេស ព្រះអង្គបានធ្វើនូវប្រយោជន៍ដល់សត្វលោកទាំងពួង ព្រះអង្គមានព្រះហ្ឫទ័យប្រទូ្បទៅដោយសេចក្តីករុណាដល់សត្វអស់កាលទាំងពួង សេចក្តីសួស្តីទាំងឡាយទាំងពួងសូមកើតមានដល់ខ្ញុំ។

ឯសត្វដង្កូវនោះពោលបទព្រះគាថានេះចប់ហើយ ទូលអំពីសេចក្តីខ្លួននឹងសត្វក្អែកសព្វគ្រប់ប្រការ ថ្វាយដល់ព្រះសម្មាសម្ពុទ្ធជាម្ចាស់" ។

គ្រានោះព្រះភគវន្តបពិត្រវិជិតមារជាម្ចាស់ ទ្រង់បានជ្រាបអជ្ឈាស្រ័យចិត្តសត្វទាំងពីរនោះហើយ ទ្រង់ក៏សួរទៅនឹងសត្វដង្កូវនោះថា "ភោ មហា កិមិន ម្នាលសត្វដង្កូវធំដ៏ចំរើន អ្នកសួរបញ្ហាទាំង ៤ នោះគឺបញ្ហាដូចម្តេចខ្លះ" ។

ឯសត្វជង្ហុកទូលថា "បពិត្រព្រះអង្គ ខ្ញុំម្ចាស់បានសួរបញ្ហាមួយទៅនឹងសត្វក្អែកថា "ធំហើយធំក្រៃលែងគឺអ្វី" ក្អែកនេះឆ្លើយថាទេវតាធំដោយវិសេស" ។

ព្រះដ៏មានព្រះភាគទ្រង់ស្តាប់ហើយក៏សួរទៅសត្វក្អែកថា ម្នាលសត្វក្អែកពាក្យនេះពិតមែនឬ ។

សត្វក្អែកទូលថា "បពិត្រព្រះអង្គដ៏បំរើន ពាក្យនេះខ្ញុំពោលពិតមែន ។

ព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់ពោលដោះស្រាយបញ្ហានេះថា "ម្នាលសត្វក្អែក អ្នកឯងមិនបេះមិនដឹងមែន ឯធំហើយធំក្រៃលែងនោះមិនមែនទេវតាឡើយ គឺលោកុត្តរធម៌ទាំង ៩ ជាធម៌ធំដោយវិសេសជាងសភាវៈទាំងពួងក្នុងលោក"

សត្វជង្ហុកស្តាប់ហើយមានចិត្តត្រេកអរថ្វាយសព្ទសាធុការថាសាធុ ៗ ប្រពៃហើយ ៗ ចំណែកខាងបញ្ហានេះបពិត្រព្រះអង្គដ៏បំរើន ខ្ញុំបានសួរបញ្ហា ១ តទៅទៀតថា "ឆាប់រហាស់ហើយឆាប់រហាស់ក្រៃលែងគឺអ្វី" សត្វក្អែកនេះឆ្លើយថា "សត្វសេះអស្សតរជាសត្វឆាប់រហាស់វិសេសជាងសត្វទាំងពួង"

ព្រះដ៏មានព្រះភាគ ទ្រង់ស្តាប់ហើយសួរទៅសត្វក្អែកវិញ ថា "ម្នាលសត្វក្អែក ពាក្យនេះពិតមែនឬ" ។

សត្វក្អែកទូលថា "បពិតព្រះអង្គដ៏ចំរើន ពាក្យនេះខ្ញុំ ពោលពិតមែន" ។

ព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ពោលដោះស្រាយបញ្ហានេះ ថាៈ "ម្នាលសត្វក្អែក អ្នកឯងមិនបេះមិនដឹងមែន ឯធាប់ រហាស់ហើយធាប់រហាស់ក្រៃលែងនោះ មិនមែនសេះអស្សតរ ឡើយ គឺដួងចិត្តដែលស្ថិតនៅត្រង់បេះដូង ជាធម្មជាតធាប់ រហាស់គ្មានវត្ថុអ្វីដទៃបិទបាំងបាន នឹកទៅត្រឹមណាបិត្តក៏ត្រេប ទៅត្រឹមនោះ១រំពេច" ។

សត្វដង្កូវស្តាប់ហើយត្រេកអរណាស់ ថ្វាយសព្ទសាធុការ ថាសាធុ ៗ ហើយទូលថា "បពិត្រព្រះដ៏មានព្រះភាគដ៏ចំរើន ខ្ញុំបានសួរបញ្ហាមួយតទៅទៀតថា "ធម្មជាតធាប់ហើយមុតក្រៃ លែងគឺអ្វី. សត្វក្អែកឆ្លើយថាកូនសរធាប់ហើយមុតក្រៃលែង ។

ព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ពោលដោះស្រាយបញ្ហានេះ ថា "ម្នាលសត្វក្អែកអ្នកឯងមិនបេះមិនដឹងមែន. ឯធាប់ហើយ មុតក្រៃលែងនោះ មិនមែនកូនសរឡើយគឺទឹក ធម្មតាឯទឹក

ទាំងអស់នេះមុតធាប់ជ្រួតជ្រាបទៅក្នុងវត្ថុទាំងអស់ក្នុងលោកពុំសល់បាន ទើបឈ្មោះថាធម្មជាតមុតដ៏ក្រៃលែង ។

ឯសត្វជង្ហវិបាកស្តាប់ហើយ ថ្វាយសព្ទសាធុការថាសាធុ ៗ ហើយពោលថា "បពិត្រព្រះដ៏មានបុណ្យដ៏បំរើន ខ្ញុំបាទសួរបញ្ហាមួយទៀតទៅនឹងសត្វក្អែកនេះថា ខ្លាំងក្រៃលែងខ្លាំងគឺអ្វី. "សត្វក្អែកនេះឆ្លើយថាព្រះនារាយណ៍មានកំឡាំងខ្លាំងក្រៃលែងខ្លាំង" ។

ឯព្រះដ៏មានព្រះភាគព្រះអង្គសួរទៅនឹងសត្វក្អែកវិញថា: "ម្នាលសត្វក្អែកពាក្យនេះ ពិតមែនឬ." ។

សត្វក្អែកក៏ទូលតបទៅព្រះដ៏មានព្រះភាគវិញថា: "បពិត្រព្រះអង្គដ៏បំរើន ពាក្យនេះខ្ញុំពោលពិតមែនព្រះអង្គ"

ព្រះលោកនាថជាម្ចាស់ ទ្រង់ត្រាស់សំដែងដោះស្រាយបញ្ហាថា: "អ្នកឯងមិនចេះមិនដឹងមែន ឯខ្លាំងក្រៃលែងខ្លាំងនោះមិនមែនព្រះនារាយណ៍ឡើយ គឺអង្គព្រះអរហំសម្មាសម្ពុទ្ធជាបុគ្គលខ្លាំងដោយវិសេសជាងបុគ្គលទាំងពួងក្នុងលោក" ។

ឯសត្វជង្ហវិបាកស្តាប់បញ្ហាព្យាករណ៍នេះ ហើយមានចិត្តរីករាយ ថ្វាយសព្ទសាធុការថាសាធុ ៗ ហើយពោលបំពោះទៅ

នឹងសត្វក្អែកនោះវិញថា ម្នាលសត្វក្អែកដ៏បំរើនពាក្យដែលអ្នកដោះបញ្ហានឹងខ្ញុំ ពុំសមពុំត្រូវតាមពាក្យព្យាករណ៍របស់ព្រះសម្មាសម្ពុទ្ធឡើយ អ្នកឯងមិនត្រូវស៊ីខ្ញុំជាចំណីឡើយ ។

សត្វក្អែកស្ដាប់ហើយពោលថាៈ "ម្នាលសត្វជង្ហុកចំណែកខាងអញក៏ពុំត្រូវការនឹងស៊ីអ្នកជាចំណីដែរ" ។

គ្រានោះព្រះដ៏មានព្រះភាគ ព្រះអង្គមានព្រះបន្ទូលទៅនឹងសត្វក្អែកថាៈ "ម្នាលសត្វក្អែក ចាប់ដើមអំពីថ្ងៃនេះទៅអ្នកឯងត្រូវតែបរិភោគអាហារដែលគួរ អាហារណាដែលពុំគួរអ្នកកុំបរិភោគអាហារនោះឡើយ" ។

ឯសត្វក្អែកបានស្ដាប់ព្រះធម្មទេសនានៃព្រះដ៏មានព្រះភាគហើយមានចិត្តត្រេកអររីករាយ ថ្វាយបង្គំលាព្រះដ៏មានព្រះភាគហើយហើរត្រឡប់ទៅកាន់ទីលំនៅខ្លួនវិញហោង ។

បំណែកខាងព្រះដ៏មានព្រះភាគព្រះអង្គមានព្រះបន្ទូលទៅនឹងមហាជនទាំងឡាយថាៈ "អ្នកទាំងឡាយត្រូវកាន់យកសត្វជង្ហុកនេះ ទៅដឹកលក់ទុកក្នុងភោជនសាលាហើយត្រូវរក្សាឲ្យល្អកុំប្រែហែសធ្វេសឡើយ" ។

ឯមហាជនទាំងឡាយ ក៏បានទទួលព្រមតាមបង្គាប់ព្រះដ៏មានព្រះភាគនោះហើយ បានចាត់ចែងរក្សាដង្កូវនោះដោយល្អពុំដែលឲ្យមានសៅហ្មងឡើយ ។

រីសត្វដង្កូវធំនោះរសនៅបាន ២-៣ ថ្ងៃហើយធ្វើមរណកាលខ្សែជីវិតទៅដោយសមគួរតាមកម្មរបស់ខ្លួន ។

លុះដល់កាលជាខាងក្រោយ ព្រះសាស្តាចារ្យជាម្ចាស់ព្រះអង្គទ្រង់សំដែងសរសើរនូវប្រាជ្ញាថាជាគុណជាតិប្រសើរដោយវិសេស អាចដោះទុក្ខខ្លួននឹងអ្នកដទៃបានដោយងាយជាបទព្រះគាថាថា: "អហំបិជាតិកោហុត្វា សុត្តសោមោចបាកដោ បញ្ញាយបរិមុញ្ចាមិ បោរិសាទស្សហត្ថតោ ។ (អធិប្បាយថា) ព្រះតថាគតបានយោនយកកំណើតកើតប្រាកដ ជាស្តេច ១ ព្រះអង្គទ្រង់ព្រះនាមព្រះបាទ សុត្តសោមបណ្ឌិត អាចដោះខ្លួននឹងស្តេចដទៃជាច្រើន ឲ្យរួចអំពីកណ្តាប់ដៃនៃស្តេចកម្ទេងបោរិសាទបាន ដោយបញ្ញា ។ អហំបិជាតិកោ មហោសថោចបាកដោ វាជាតោបរិមុញ្ចាមិ បញ្ញាយចមេភវិស្សតិ ។ (អធិប្បាយថា) ប្រាជ្ញឯណាមានប្រាកដដល់តថាគត ៗ យោនយកកម្ចើតកើតប្រាកដជាអ្នកប្រាជ្ញឈ្មោះមហោសថ បានដោះនូវស្តេចទាំង

ខ្លាយខ្សែរូបចាកទុក្ខបាន ដោយប្រាជ្ញានោះ ។ អហំបិជាតិ-កោហុត្វា វិធុរោនាមបណ្ឌិតោ បញ្ញាយបរិមុញ្ចាមិ បុណ្ណ-យក្ខស្សហត្ថតោ អន្តមសោបិសត្តោច កិមិនោចយថាសុខំ បញ្ញាយបរិមុច្ចតិ កាកស្សមរណតោច ។ (អធិប្បាយថា) ព្រះតថាគតបានយោនយកកំណើតកើតប្រាកដ ជាអ្នកប្រាជ្ញ ឈ្មោះវិធុរបណ្ឌិត អាចដោះខ្លួនខ្សែរូបអំពីកណ្ដាប់ដៃនៃបុណ្ណ-យក្សបាន ដោយបញ្ញា ម្យ៉ាងទៀតដោយហោចទៅ សូម្បីតែ សត្វជង្គរ កំអាចដោះខ្លួនខ្សែរូបអំពីសេចក្ដីមរណៈកើតអំពីសត្វ ក្អែកបៀតៈបៀន ដោយសមគួរតាមសុខ សំរេចបានដោយ ប្រាជ្ញាខ្លួន ព្រះអង្គមានព្រះភាគទ្រង់សំដែងគាថានេះចប់ហើយជន ទាំងឡាយក៏បានសំរេចនូវមគ្គនឹងផលជាច្រើនក្នុងលោកនេះ.

( សម្ដែងរឿងប្រស្នាសត្វជង្គួរនឹងសត្វក្អែកចប់សេចក្ដីសង្ខេបតែប៉ុណ្ណេះ )

# កាព្យថ្លែងលោកធម៌ ៨ ប្រការ

ព្រះសាសនសោភ័ណ ជ. ណាត់ ចាងហ្វាងរងនៅសាលាបរិយត្តិជាន់ខ្ពស់

រៀបរៀង



ខ្ញុំឈ្មោះអក្សរណាផ្សំស្រែអា ដាក់តមុខជាតួបង្ហើយ ជាតួប្រកបពុំអានឡើយ ឲ្យដល់ស្របចុងដូចបាឡីៈ។ មានកាលយប់មួយឥតកង្វល់ ខ្វាយខ្វល់អំពីរឿងហេតុអ្វី មានកិច្ចតែខាងមើលបាឡី ដែលព្រះជិនស្រីទ្រង់ទេស្នា ។ ខ្ញុំមើលត្រង់លោកធម្មសូត្រ រហូតដល់ចប់ព្រះគាថា មើលបណ្ដើរគិតបណ្ដើរដោយចិត្ត គិតថាចង់ប្រែជាសម្រាយ ។ ជាប្រយោជន៍ដល់ជនអ្នកត្រូវការ ចង់បេះធម៌អាថ៌តាមអភិប្រាយ អ្នកដែលមិនបេះខាងប្រែស្រាយ បើពាក្យសម្រាយច្រើនចូលចិត្ត ។ ខ្ញុំបានផ្ដើមតែងជាពាក្យកាព្យ តាមសភាពប្រាជ្ញាខ្ញុំរិះគិត ដម្រូវតាមធម៌ដែលមានពិត ប្រតិដ្ឋប្រដូចឲ្យងាយ

យល់ ។ ខ្ញុំតែងជាកាព្យបម្រុសពាក្យ ប្រាំពីរប្រាំបីតាមយោ-
បល់ ឃ្លាខ្លះមានកើនរហូតដល់ ប្រាំបួនពាក្យផ្តល់តាមសេច-
ក្ដី ។ ខ្ញុំសូមសំដែងបែងពីធម៌ ដ៏បវរសម្រាប់ជនប្រុសស្រី
ឈ្មោះហៅលោកធម៌មានប្រាំបី ជាសង្ខុបខ្លីៗ តាមគាថា ។
ធម៌ទាំងប្រាំបីប្រការនោះ មានឈ្មោះតាមបាលីភាសា លាភោ
មានលាភផងនានា ទោះស្រែចំការទោះមាសប្រាក់ ។ អលា-
ភោ ឥតលាភឬខាតបង់ ខុសបំណងយ៉ាងបំណុបទាស់ទើស
ទាក់ មុខស្រពោនខ្លួនស្រពន់ចិត្តអន់អាក់ គំនិតរាក់ប្រាជ្ញា
រលំមិនយល់ឆ្ងាយ ។ យសោ មានយសស័ក្ដិថ្កើងថ្កាន បាន
អ្វីក៏បានមកដោយងាយ តេជះតបះក៏ផ្សព្វផ្សាយ ជនទាំង-
ឡាយធំតូចសំរាប់អាន ។ អយសោ ឥតយសឬប្លស់យស
ខ្ពស់ចុះជាទាបមិនសមប្រាណ ថយអំណាចតេជះមិនក្លាហាន
ញានអ្វីក៏បានដោយលំបាក ។ និន្ទា អ្នកផងគេតិះដៀល ចាក់
ផ្ចៀលដោយលំពែងគឺមាត់ពាក្យ ត្រគោះបោះបោកៗ ខ្លោកខ្លាក
ជ្រោកជ្រាករិះគន់ពោលបង្អាប់ ។ បសំសា វាចាគេសរសើរ
បង្ហើរសំដីដោយប្ញូរបាច់ ឆ្ពោះមុខឬកំបាំងគេថាស្រែប នឹងខ្លួន
ហើយដាប់គេទាំងអស់ ។ សុខំ សុខកាយសុខទាំងចិត្ត ឥត-

មានក្តីទុក្ខមកទើសទាស់ នេះនោះទាំងគ្រប់ស្រួលគ្មានខ្វល់ ខ្ពង់ខ្ពស់ថ្លៃថ្លាពេញបំណង ។ ទុក្ខ គឺក្តីទុក្ខក្តៅក្ខួល រំជួលជ្រួលច្រាល់មិនសមប៉ង នាំកាយនឹងចិត្តឲ្យសៅហ្មង ឲ្យអ្នកផងគេព្រួយតែរាល់ប្រាណ ។ ធម៌នេះរាប់រាយមានប្រាំបី បើផ្គុំឲ្យខ្លីជាគូបាន ត្រឹមតែបួនគូគត់តាមឋាន កើតបានតែមួយមួយឈប់កើត ។ ផ្លះប្តូរដោរវេនៗតាមគូ វិញ្ញូអ្នកប្រាជ្ញដែលបេះដើតកំណត់សំគាល់ស្គាល់កំណើត ទោះធម៌ណាកើតក៏អាចដឹង ។ ព្រះពុទ្ធទ្រង់ត្រាស់សំដែងថា ឲ្យអស់បណ្ឌាជនផងប្រឹង យកចិត្តទុកដាក់គិតជញ្ជឹង រំពឹងនឹកដល់ការប្រែប្រួល ។ ប្រយ័ត្នគំនិតប្រុងស្មារតី ទោះបីសុខទុក្ខស្រួលពុំស្រួល កើតហើយបាត់ទៅតាមដំណួល ត្រូវគិតសម្រួលតាមការពិត ។ សត្វ-លោកតែងស្មោកព្រោះលោកធម៌ បានអរបង់អន់ស្រពន់ចិត្ត មានយសខ្ពង់ខ្ពស់រីករាយឥត មានគំនិតគិតដល់ប្លស់យស់ឡើយ ។ កាលបើបានឮពាក្យនិន្ទា ផ្តោះអាត្មាឱរាក្តៅមិនស្បើយ បើបានឮគេសរសើរហើយ ចិត្តពុំកន្តើយអរផើតៗ ។ បានសុខភ្លេចនឹកដល់ទុក្ខ កើតកំឡាំងក្លាខ្លាំងឥតញញើត

ញញឹមញញយ ៗ ចិត្តព្រឺព្រើត រកកល់គេទើតទាស់ពុំបាន ។ លុះដល់អស់វេនសេចក្ដីសុខ ធ្លាក់វេនក្ដីទុក្ខមកដល់ប្រាណ ស្រាប់តែព្រួយរកគេឲ្យជួយប្រាន ទុក្ខនោះឲ្យក្សាន្តពីអត្តភាព ។

សុខក្ដីទុក្ខក្ដីរបស់សត្វ ខ្វាត់ទៅមកវិញតាមសភាព បុណ្យបាបដែលធ្វើមករៀងរាប ស្ទាប ៗ ឲ្យផលដល់អាត្មា ។ ព្រះសម្ពុទ្ធជាមកុដនៃត្រៃភព ទ្រង់ប្រារព្ធធម៌នេះហើយត្រាស់ថា ឲ្យសត្វរិះគិតដោយប្រាជ្ញា កុំសាវាតាមតែចិត្តដែលប្រទុះ ។ បានលាភត្រូវនឹកដល់ការបង់ បានយសស័ក្តិរុងរឿងតេជះ កុំកក្អិលក្អេងក្អាងដោយមានះ ត្រូវនឹកខ្លះកុំភ្លេចការប្រែប្រួល ។ បើឮអ្នកផងគេនិន្ទា ដល់អាត្មាត្រូវតាំងចិត្តសម្រួល សម្រាកក្ដីក្រោធកុំរំជួល ទុកជាក្តួលក្ដៅម្ដេចត្រូវខំអត់ ។ គប្បីគិតភ្លាមថានិន្ទា នេះជាគ្នានឹងសរសើរជាប្រាកដ បើអញតាំងចិត្តជាអំណាត់ រាល់មាត់គេនឹងសរសើរអញ ។ ថានេះហៅពេញជាបេះអត់ បេះសង្កត់កំហឹងដែលខឹងក្ដាញ់ ធ្វើអ្នកស្អប់ឲ្យត្រឡប់ជាស្រឡាញ់ បានសុខព្រោះផ្ចាញ់សេចក្ដីក្រោធ ។

មួយទៀតមានពាក្យសុភាសិត អ្នកប្រាជ្ញប្រតិដ្ឋជាបំណោទ ថាកាលបើមានសេចក្ដីក្រោធ កុំប្រទេះ្ឡាតត្រូវរាប់អក្សរសិន ។ រាប់អក្សរកខដល់ឡអ៊ង រួបសំកាំងទ្រឹងទឹកគិតដង្វិន(១) គួរ គ្នាន់រកហេតុរកផលសិន បើប្រសិនក្រោធល្មមគង់នឹងស្រាក ។ ពុំនោះលោកថាឲ្យរាប់លេខ ពីឯកដល់ទសឈប់សម្រាក ទ្រាំងមួយស្របក់នឹងបានស្រាក ឃ្លាតចាកកំហឹងដ៏ឃោរឃៅ ។ បើបានប្រកបដោយក្ដីសុខ ឃ្លាតចេញពីទុក្ខសោកហ្មងសៅ កុំអាលអរអេកត្រេកសំដៅ ដូចកង្កែបខែក្ដៅត្រូវភ្លៀងធំ ។ គប្បី តាំងចិត្តគិតទៅមុខ ហាត់ឡូវផែនសុខមកអភិរម្យ មុខជាដល់ ថ្ងៃណានឹងរលំ ទុក្ខតូចឬធំមកពុំខាន ។ អ្នកណាបានសុខ ធំទូលាយ ដល់ផែនទុក្ខផ្សាយមកដល់ប្រាណ នឹងបានទុក្ខធំ ពន់ប្រមាណ តាមលំអានស្មាមសុខដែលកើតមុន ។ ហេតុ នោះគួរអស់សាធុជន កុំទម្រន់គំនិតឲ្យលង់ស៊ុន ក្នុងលោក ធម៌ណាដែលកើតមុន ទោះស្រាលទោះធ្ងន់ក្ដីសុខទុក្ខ ។ ទោះ-

(១) ដង្វិន ពាក្យខ្មែរបូរាណថា "ពិចារណា, ត្រិះរិះ; ស្ទង់" ។

លាភទោះយសទោះខាតបង់ ទោះលិចលង់ឬស់យសមិនពេញ មុខ ទោះសរសើរទោះនិន្ទាថាកំព្រុក ត្រូវតែតាំងចិត្តទុកជា មធ្យម ។ លុះបានតាំងចិត្តទុកដូច្នេះ ទើបរបេះឃ្លាតខ្លះពីទុក្ខទំ ដោយហេតុមិនដូចចិត្តឲ្យធំ ឲ្យរង្គំនៅក្នុងកន្លែងមួយ ។ បើមាន ប្រាជ្ញាប្រយោគដល់ ហេតុនឹងផលដែលមានតាមជម្រួយ ទើប ចិត្តនឹងអាចឃ្លាតចាកព្រួយ បើទុកជាព្រួយក៏គ្រាន់ទ្រាំ ។ ពីព្រោះបានដឹងច្បាស់ការពិត ដោយគំនិតត្រិះរិះដ៏ម្ហូនមាំ ដឹង ថាលោកធម៌កើតជោកជាំ សាំទាំនៅក្នុងសន្តានសត្វ ។ កើត មានមិននឹងតែមួយ ៗ ដួនព្រួយដួនអរមានបាត់ ៗ ហើយ មានឡើងវិញមិនទៀងទាត់ មួយកើតមួយបាត់ផ្លាស់ប្តូរគ្នា ។ បើដឹងដូច្នេះហើយគួរខំ អប់រំប្រាជ្ញាឲ្យក្លៀវក្លា គួរគិតគួរគ្នេរ ពិចារណា សិក្សារៀនសូត្រកុំធុញទ្រាន់ ។ គួរប្រឹងសង្កេតធម៌ បរមត្ថ មានអត្ថជ្រាលជ្រៅជាអនន្ត ប្រាប់ផ្លូវមគ្គផលមិនមាន ភាន់ មានថ្នាក់មានជាន់តាមលំដាប់ ។ សត្វដែលនឹងបានរួប ចាកទុក្ខ ព្រោះធុញធួរមុខនឹងកើតស្លាប់ មានគំនិតដូចសត្វទទា

ជាប់ ក្នុងទ្រង់មិនគាប់ក្ដីប្រាថ្នា ។ បេះតែស្មុះប្រាស់ប្រាល់ជាល់ បិកទ្រុង បង់ឲ្យរលុងនឹងម្ចម្នា ស្ទុះបេញឡើរូបហើយនឹងលោ ត្រជាងស្លាបវាហើយហើរទៅ ។ អ្នកដែលធុញទ្រាន់នឹងកើត ស្លាប់ ចង់ប្រញាប់បេញចាកបោលលំនៅ គឺវដ្ដសំសារនេះ ហើយទៅកាន់លំនៅមានទុក្ខរលត់បង់ ។ មគ្គផលនឹងមាន ព្រោះអាស្រ័យ ចិត្តជាប់អាល័យពីចំណង់ ហើយស្ម័គ្រនឹង ដើរតាមផ្លូវត្រង់ ប្រកបដោយអង្គប្រាំបីយ៉ាង ។ ហៅថា អដ្ឋង្គិកមគ្គ ឥតអ្វីទើសទាក់ឥតវៀចវាង ស្រួលដើរបំផុត ដល់អ្នកសាង មានសំណាងដូចយ៉ាងព្រះសុគត ។ ផ្លូវនេះ ជាហេតុជាឧបាយ ឲ្យសត្វទាំងឡាយបានរលត់ ភ្លើងទុក្ខ ហើយលែងមានវត្ត ព្រោះលោកធម៌ទាំងប្រាំបី ។ ឈ្មោះ ហៅថាបានព្រះនិព្វាន ជានិរោធដ្ឋានគ្មានទុក្ខភ័យ សុខក្រៃ លែងសុខឥតទុក្ខអ្វី មកប៉ះមកពាល់ដល់តិចឡើយ ។ ជា ស្ថានគ្មានចាស់គ្មានឈឺចាប់ គ្មានកើតគ្មានស្លាប់សុខក្ដើយ ព្រះពុទ្ធទ្រង់ត្រាស់ហៅថាត្រើយ អ្នកទៅដល់ហើយលែងមក វិញ ។ ជាទីឥតកិច្ចការគ្រប់យ៉ាង ឥតសង់ឥតសាងឥតលក់

ទិញ មានតែសុខមួយយ៉ាងជាបំណោញ ឈ្មោះថាបេញពាក ទុក្ខស្រទម្លះហោង ។

សេចក្ដីនេះពិតជាពាក្យកាព្យ តែមិនមែនកំណាព្យពាក្យ ផ្ដាំផ្ដង ជាសាប់ធម៌មែនឥតមោះហ្មង គ្រាន់តែក្រងជាពាក្យ មានឃ្លោងឃ្លា ។ សូមអស់អ្នកប្រាជ្ញរាជករ កុំបីបន្ទោស ជៀលនិន្ទា កាព្យនេះខ្ញុំតែងតាមមាត្រា សម្មស្សរាំវាចាពុំមាន ល្មៀង ។ តាមច្បាប់មេកាព្យវិសាលិនី វិធីអ្នកប្រាជ្ញលោក រៀបរៀង ជាច្បាប់សម្រាប់គ្រាន់ផ្ទឹមផ្ទៀង ឲ្យទៀងតាមបែប ខ្សល់អក្សរ ។ ឥតិ ឯវំ មេ កាព្យោ បរិបុណ្ណោ តាមសាប់ធម៌ សុខិតា ហោន្តុ សត្តនិករ បួរបានអំណរសុខគ្រប់គ្នា ។៙—

# រឿងព្រេងខ្មែរ

ស្រង់យកពីសៀវភៅលោកអេម៉ូនិញេ

— ១ —

## រឿងខ្លា

នៅក្នុងនគរ ១ មានស្តេចសោយរាជក្នុងនគរនោះ ឯស្តេចនោះបានសោយរាជឡើងកាលណា ក៏គិតក្នុងព្រះទ័យថាបើមានខ្មាំងសត្រូវឯណាគេលើកមកវាយនគរ ហើយយើងគ្មានបំណេះវិជ្ជាការអ្វីនឹងការពាររក្សានគរ ស្តេចនោះគិតដូច្នោះហើយ លុះដល់វេលាព្រឹកស្តេចចេញចុងព្រះរាជវាំងជុំអស់នាម៉ឺនមុខមន្ត្រីស្តេចមានបន្ទូលនឹងអស់នាម៉ឺន ថាបើសិនណាមានខ្មាំងសត្រូវគេលើកមកវាយដណ្តើមយកនគរយើង ក្នុងនគរយើងនេះ គ្មានស្តេចនាម៉ឺនឯណាដែលចេះវិជ្ជាការបំណេះខាងបំបាំងឡើយ បើដូច្នេះយើងទៅរករៀនបំណេះរៀនខាងបំបាំងឲ្យពូកែ នឹងបានរក្សាស្រុករក្សានគរ កុំឲ្យខ្មាំងសត្រូវឯណា

ច្បាំងដណ្ដើមយកនគរយើងបាន ស្ដេចមានព្រះបន្ទូលដូច្នោះហើយ អស់នាម៉ឺនសព្វមុខមន្ត្រីចូលចិត្តព្រមជាមួយនឹងស្ដេច ហើយស្ដេចឱ្យសម្ដេចចៅហ្វានៅរក្សានគរជាមួយនឹងសព្វមុខមន្ត្រី ហើយយកមហេសីនឹងហោរ៉ាន្ទរិបតុស្ដម្ភទាំង ៤ ទៅជាមួយនឹងស្ដេចទៅនគរតក្កសិលា រៀនបំណេះវិជ្ជាការពីអាចារ្យទិសាបាមោក្ខ ។

ឯស្ដេចនឹងមហេសីនឹងហោរ៉ាន្ទរិនាម៉ឺនចតុស្ដម្ភទាំង ៤ លុះទៅដល់នគរតក្កសិលាហើយចូលទៅកាន់ផ្ទះអាចារ្យទិសាបាមោក្ខហើយសូមរៀនសិល្បសាស្ត្រពីអាចារ្យទិសាបាមោក្ខទាំង ៧ នាក់ លុះរៀនសិល្បសាស្ត្រចេះចប់សព្វគ្រប់ហើយក៏លាអាចារ្យត្រឡប់មកនគរវិញ លុះដល់មកពាក់កណ្ដាលផ្លូវហើយអត់បាយគ្មានស្រុកគេនៅ ហើយស្ដេចទ្រង់ព្រះបិត្តានឹងអគ្គមហេសីនឹងហោរ៉ាន្ទរិបតុស្ដម្ភទាំង ៤ ថាយើងឥឡូវនេះអត់បាយគ្មានភូមិស្រុកគេនៅ បើដូច្នេះយើងល្បងចំណេះរបៀនដែលយើងរៀនមក បើយើងនឹងដំណែងធ្វើជាខ្លាចាប់សត្វស៊ីក្នុងព្រៃនេះឱ្យឆ្អែត មានកំឡាំងហើយសិមយើងទៅទៀត គិត

ព្រមគ្នាដូច្នោះហើយ ស្ដេចដំរីណែងធ្វើជាមុខខ្លា ឯអគ្គមហេសី ធ្វើជាខ្លួន ហោរ៉ាធ្វើជាកន្ទុយ ចតុស្ដម្ភទាំង ៤ ធ្វើជាជើងទាំង ៤ ហើយចូលទៅក្នុងព្រៃ រកចាប់ប្រើសក្ដាន់ស៊ីជាចំណីសប្បាយក្នុងចិត្ត លុះដល់ពីរបីថ្ងៃភ្លេចគិតត្រឡប់មកជាមនុស្សវិញ ដោយសប្បាយក្នុងព្រៃ បានចំណីស៊ីឆ្អែតក៏នៅជាសត្វខ្លា លុះដល់សព្វថ្ងៃឥឡូវនេះបានជាសត្វខ្លាមានមុខសំបើម ពីព្រោះអំណាចស្ដេចនៅខាងក្បាល ឯខ្លួនខ្លានោះអគ្គមហេសីជាស្រី បានជាខ្លួននោះតូចបង្កេះនោះរៀវដោយសាជាស្រី ឯហោរានោះនៅកន្ទុយជាប្រផ្នូលតែងបួល បើថ្ងៃណាអត់ចំណីខ្លានោះបួលនឹងកន្ទុយ បើកន្ទុយនោះបក់ទៅទិសណា ខាងណា ខ្លាក៏ទៅតាមខាងនោះ បានចំណីស៊ីឆ្អែតបរិបូណ៌ដោយសារកន្ទុយនោះឯង ហើយមានឆ្នូត ៣ ពីព្រោះមនុស្ស ៣ នាក់ទៅក្រឡាជាសត្វ ធ្វើជាសត្វខ្លាបានជាមានឆ្នូត ៣ ហើយមានកំឡាំងក៏ខ្លាំង លុះដរាបមកដល់សព្វថ្ងៃនេះ ។ ៚

( និយាយរឿងព្រេងអំពីសត្វខ្លាអស់ដំណើរតែប៉ុណ្ណោះ )

ECOLE FRANÇA[ISE] BIBLIOTHÈQU[E]